# បញ្ជីរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសាលាក្តីខ្មែរក្រហម ស្តីពីសវនាការខ្មែរក្រហម លេខ៣១ ដល់លេខ៤០ ជាភាសាខ្មែរ

| របាយការណ៍លេខ | សវនាការលើភស្តុតាង | ការសង្ខេប | តភ្ជាប់ |
|---|---|---|---|
| ៣១ | សប្តាហ៍ទី២៦ ថ្ងៃទី០៦ ខែសីហា - ទី០៩ ខែសីហា ឆ្នាំ២០១២ | លោក **សួង ស៊ីគឿន** ជាអតីតកម្មាភិបាលជាន់ខ្ពស់មួយរូបពីក្រសួងការបរទេស បានបន្តផ្តល់សក្ខីកម្មរបស់ខ្លួនក្នុងសប្តាហ៍នេះ។ គាត់បានផ្តល់ឲ្យអង្គបុរេជំនុំជម្រះសាលាដំបូងយ៉ាងលម្អិតអំពីតួនាទីរបស់គាត់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការប្រាស្រ័យគ្នារវាងគាត់ និងរដ្ឋមន្ត្រីក្រសួងការបរទេស គឺជនជាប់ចោទ **អៀង សារី**។ សាក្សីក៏បានផ្តល់សក្ខីកម្មផងដែរថា ចំពោះការអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងចម្លើយសារភាព និងការចាប់ខ្លួនមនុស្សក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។<br>កាលពីថ្ងៃអង្គារ អង្គជំនុំជម្រះសាលាដំបូង បានពន្យារពេលសវនាការក្នុងការស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះ ដោយពិចារណាពីស្ថានភាពសុខភាពរបស់គាត់ និងបានកោះហៅសាក្សីបម្រុងម្នាក់ទៀតគឺលោក **អ៊ុង ចុងហឿង** ជាបញ្ញវន្តមួយរូបដែលបានទទួលការសិក្សានៅប្រទេសបារាំង និងក៏ជាបុគ្គលម្នាក់ដែលបានត្រឡប់មកប្រទេសកម្ពុជាវិញ ជាមួយនឹងក្តីសង្ឃឹមយ៉ាងមុតមាំថានឹងបានរួមចំណែកកសាងប្រទេសកម្ពុជា បន្ទាប់ពីការដួលរលំនៃរបប **លន់ នល់**។ សាក្សី **អ៊ុង ចុងហឿង** បានផ្តល់នូវព័ត៌មានស្តីពីការពាក់ព័ន្ធរបស់លោក **អៀង សារី** ទៅនឹងការរៀបចំចាត់ចែងដល់ក្រុមបញ្ញាជន ដែលជាជនជាតិកម្ពុជាឲ្យធ្វើមាតុភូមិនិវត្តន៍មកមាតុប្រទេសខ្លួនវិញ។ លោកបានផ្តល់សក្ខីកម្ម ដោយផ្អែកទៅលើបទពិសោធន៍ផ្ទាល់ខ្លួនមួយចំនួនក្នុងជំរំអប់រំកែប្រែ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ | http://krttrialmonitor.files.wordpress.com/2012/08/31_week26_6-9-august-2012_kh1.pdf |
| ៣២ | សប្តាហ៍ទី២៧ ថ្ងៃទី១៣ ខែសីហា -ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២ | ក្រោយពេលពន្យារពេលសវនាការកាលពីថ្ងៃចន្ទ ដោយសារតែបញ្ហាសុខភាពទន់ខ្សោយរបស់ជនជាប់ចោទលោក **អៀង សារី** សវនាការបានបន្តនៅថ្ងៃអង្គារនេះ ដោយបានបញ្ចប់ការផ្តល់សក្ខីកម្មរបស់លោក **អុង ចុងហឿង** ដែលជាបញ្ញវន្តម្នាក់បានត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ហើយគាត់បានធ្វើការងារហត្ថកម្មនៅក្នុងជំរំអប់រំរៀនសូត្រ ដើម្បីធ្វើការ “កសាង” ខ្លួន។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានកោះហៅលោក **សួង ស៊ីគឿន** ដែលជានាយកព័ត៌មាន និងឃោសនាការនៃក្រសួងការបរទេស ដើម្បីមកបន្តសក្ខីកម្មរបស់គាត់។ លោក **សួង ស៊ីគឿន** បាននិយាយពីក្រសួងការបរទេសរណសិរ្សរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយនិងតួនាទីរបស់ **ប៉ុល ពត** ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ។ ដោយពិចារណាទៅលើសុខភាពទ្រុឌទ្រោមរបស់គាត់ អង្គជំនុំជម្រះសាលាដំបូង បានកំណត់ការសួរដេញដោលគាត់ត្រឹមតែកន្លះថ្ងៃ។ ដើម្បីគ្រប់គ្រងពេលវេលាឲ្យមានប្រសិទ្ធភាព សាក្សីបម្រុងអ្នកស្រី **ស សៀក** (ដែលមានអត្តលេខ TCW-609) ដែលជាកម្មាភិបាលមួយរូបធ្វើការនៅក្រសួងឃោសនាការក្នុងអំឡុងនៃរបបនេះ បានចាប់ | http://krttrialmonitor.files.wordpress.com/2012/08/32_-week-27-_13-16-aug-2012_kh.pdf |

| | | | |
|---|---|---|---|
| | | ផ្ដើមផ្ដល់សក្ខីកម្មរបស់គាត់។ អ្នកស្រី **ស សៀក** បានផ្ដោតទៅលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ រចនាសម្ព័ន្ធក្រសួងឃោសនាការ និងការផ្សព្វផ្សាយវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យ។ | |
| ៣៣ | សប្ដាហ៍ទី២៨ ថ្ងៃទី២០ ខែសីហា - ទី២៣ ខែសីហា ឆ្នាំ២០១២ | ដោយមានការខ្វះខ្វែងពីសំណាក់អង្គជំនុំជម្រះ ក្នុងការពន្លឿនដំណើរការនីតិវិធី សក្ខីកម្មចំនួនបួន ត្រូវបានធ្វើឡើងពេញមួយសប្ដាហ៍នេះ។ លោក **សួង ស៊ីគឿន** ជាកម្មាភិបាលជាន់ខ្ពស់នៃក្រសួងការបរទេស និងលោកស្រី **ស សៀក** ជាអ្នកសិល្បៈនៃក្រសួងឃោសនាការ និងអប់រំ បានបញ្ចប់សក្ខីកម្មរបស់ពួកគាត់ដែលបានធ្វើកាលពីសប្ដាហ៍មុន។ សាក្សីថ្មីមួយរូបទៀត គឺលោក **គឹម វុន** បានផ្ដល់សក្ខីកម្មពីបទពិសោធន៍របស់គាត់ជាក្មេងធ្វើការ នៅក្នុងផ្ទះបោះពុម្ពរបស់បក្ស ហើយក្រោយមកជាអ្នកថតរូប និងអ្នកនិពន្ធក្នុងក្រសួងឃោសនាការ និងអប់រំ។ លោក **គឹម វុន** បានបញ្ចប់សក្ខីកម្មរបស់គាត់ក្នុងសវនាការរយៈពេលពីរថ្ងៃ ដោយទុកពេលឲ្យអង្គជំនុំជម្រះចាប់ផ្ដើមស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីលោក **អែម អឿន** ដែលជាគ្រូពេទ្យក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានផ្ដល់សក្ខីកម្ម អំពីការអនុវត្តន៍វិជ្ជាពេទ្យ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយដែលបានដាក់ឲ្យអនុវត្តក្នុងសម័យនោះ។ | http://krttrialmonitor.files.wordpress.com/2012/08/33_week28_20-23-aug-2012_kh.pdf |
| ៣៤ | សប្ដាហ៍ទី២៩ ថ្ងៃទី២៧ ខែសីហា - ទី២៩ ខែសីហា ឆ្នាំ២០១២ | លោក **អែម អឿន** ជាដើមបណ្ដឹងរដ្ឋប្បវេណីទី៣ ដែលបានបន្តសក្ខីកម្មនៅក្នុងសប្ដាហ៍នេះ។ ក្រុមការពារក្ដីបានសួរផ្ចង់លើភាពមិនស៊ីចង្វាក់គ្នាក្នុងសក្ខីកម្មមួយចំនួនរបស់គាត់ ដូចជា៖ ភាពទាក់ទងនឹងការផ្ដល់កាលបរិច្ឆេទ ក៏ដូចជាការអត្ថាធិប្បាយនូវព្រឹត្តិការណ៍ផ្សេងៗ។ ក្រុមការពារក្ដីក៏បានសួរអំពីប្រវត្តិសិក្សាវិជ្ជាពេទ្យរបស់គាត់ ដើម្បីបំភ្លឺនូវសក្ខីកម្មកន្លងមក ដែលហាក់ដូចជាមិនស្របនឹងព័ត៌មានដែលគាត់បានផ្ដល់ នៅក្នុងទម្រង់សុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឬហៅថា ទម្រង់ព័ត៌មានរបស់ជនរងគ្រោះ។ នៅចុងបញ្ចប់នៃសក្ខីកម្មរបស់គាត់ លោក **អែម អឿន** បានបញ្ជាក់ឡើងវិញនៅចំពោះមុខអង្គជំនុំជម្រះ អំពីសុចរិតភាពនៃសេចក្ដីថ្លែងការណ៍របស់គាត់ ហើយសុំឲ្យមានការយោគយល់ពីការភ័ន្តច្រឡំកន្លងមក។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូង បានកោះហៅសាក្សីថ្មីមួយរូបទៀត គឺលោក **នង សុផង់** ជាប្រធានកងផ្នែកបកប្រែសារទូរលេខម្នាក់នៅទីក្រុងភ្នំពេញ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានផ្ដល់ចម្លើយដ៏គួរឲ្យចាប់អារម្មណ៍ ទាក់ទងនឹងរបៀបទំនាក់ទំនងដ៏សម្ងាត់បំផុតរវាងកម្មាភិបាលថ្នាក់ក្រោម និងមេដឹកនាំខ្មែរក្រហម ក៏ដូចជារចនាសម្ព័ន្ធរដ្ឋបាលនៃផ្នែកទំនាក់ទនងតាមរយៈសារទូរលេខនាពេលនោះ។ | http://krttrialmonitor.files.wordpress.com/2012/08/34-_week-29-_-hearing-on-evidence-_27-29-aug-2012.pdf |
| ៣៥ | សប្ដាហ៍ទី៣០ ថ្ងៃទី០៣ ខែកញ្ញា - ទី០៦ ខែកញ្ញា ឆ្នាំ២០១២ | កិច្ចដំណើរការនីតិវិធីសវនាការនាសប្ដាហ៍នេះ ផ្ដោតទៅលើសក្ខីកម្មរបស់សាក្សីលោក **នង សុផង់** ជាប្រធានអង្គភាពសារទូរលេខ ដែលជាអ្នកបង្រៀនបច្ចេកទេសបំភ័ន្តអក្សរនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ សក្ខីកម្មរបស់សាក្សី បានពន្យល់អំពីភាពស្មុគស្មាញនៃប្រព័ន្ធទំនាក់ទំនង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបំភ្លឺពីតួនាទីរបស់ជនជាប់ចោទ។<br>បញ្ហាផ្លូវច្បាប់ និងនីតិវិធី ក៏បានកើតឡើងយ៉ាងធំដុំផងដែរ នៅពេលដែលក្រុមមេធាវីការពារក្ដី បានធ្វើការតវ៉ាពីរបៀប ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើការស៊ើបអង្កេត។ | http://krttrialmonitor.files.wordpress.com/2012/09/35_week-30_3-6-sept-2012_kh.pdf |

| | | | |
|---|---|---|---|
| ៣៦ | សប្តាហ៍ទី៣១<br>ថ្ងៃទី២០ ខែកញ្ញា<br>- ទី២១ ខែកញ្ញា<br>ឆ្នាំ២០១២ | ដោយសារករណីជនជាប់ចោទ **អៀង សារី** នៅតែបន្តការព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត តុលាការបានធ្វើសវនាការតែពីរថ្ងៃក្នុងសប្តាហ៍នេះ។ លោក **ជា សាយ** (TCW-91) ជាអ្នកជួសជុលរថយន្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បានផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះកាលពីថ្ងៃព្រហស្បតិ៍ ។ សម្រាប់សាក្សីរូបនេះ ជនជាប់ចោទ **អៀង សារី** បានលះបង់សិទ្ធិចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការ។<br>កាលពីព្រឹកថ្ងៃសុក្រ លោកវេជ្ជបណ្ឌិត **លឹម ស៊ីវុត្ថា** និងវេជ្ជបណ្ឌិត **គី ប៊ុស្ស** ជាគ្រូពេទ្យប្រចាំកាយរបស់លោក **អៀង សារី** បានផ្តល់សក្ខីកម្មអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទរូបនេះ។ ដើម្បីបំភ្លឺនូវស្ថានភាពសុខភាពបច្ចុប្បន្នរបស់លោក **អៀង សារី** ហើយដែលបញ្ហានេះបានប៉ះពាល់នូវសិទ្ធិរបស់គាត់ក្នុងនាមជាជនជាប់ចោទម្នាក់ ដែលត្រូវបង្ហាញខ្លួនក្នុងពេលដំណើរការសវនាការ អង្គជំនុំជម្រះបានផ្តល់ពេលវេលាពេញមួយរសៀលថ្ងៃសុក្រ ដើម្បីស្តាប់មតិយោបល់ពីភាគីពាក់ព័ន្ធទាំងអស់ ធ្វើការពិភាក្សាគ្នាលើកាលវិភាគការស្តាប់សក្ខីកម្មរបស់សាក្សីជំនាញលោក **ហ្វីលីព ស្បេត** ។ | http://krttrialmonitor.files.wordpress.com/2012/09/36_week-31_20-21-sept-2012_kh.pdf |
| ៣៧ | សប្តាហ៍ទី៣២<br>ថ្ងៃទី២៥ ខែកញ្ញា<br>ឆ្នាំ២០១២ | អង្គជំនុំជម្រះ បានបន្តដោះស្រាយបញ្ហានៃការសម្របសម្រួលពេលវេលាសវនាការ ដោយសារបញ្ហាសុខភាព និងភាពមានកម្រិតនៃការលះបង់សិទ្ធិមានវត្តមានរបស់ជនជាប់ចោទ **អៀង សារី**។ ដូច្នេះ មានតែសាក្សីម្នាក់គត់ គឺអ្នកស្រី **នឹម សែម** (TCW-៤៧៥) ដែលបានផ្តល់សក្ខីកម្មនៅសប្តាហ៍នេះ។ អ្នកស្រី **នឹម សែម** ជាអ្នកចម្រៀង និងជាអ្នកអានសារព័ត៌មានឲ្យក្រសួងព័ត៌មាន និងឃោសនាការ។ អ្នកស្រីបាន ផ្តល់សក្ខីកម្មពីតួនាទីរបស់អ្នកស្រីនៅក្នុងបក្ស រចនាសម្ព័ន្ធរដ្ឋបាលនៅក្នុងក្រសួង មន្ទីរ៨៧០ ហើយនិងភាពខុសគ្នារវាងមន្ទីរ-ក មួយចំនួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រីបានបញ្ចប់សក្ខីកម្មរបស់អ្នកស្រីត្រឹមតែរយៈពេលមួយថ្ងៃ ហើយអង្គជំនុំជម្រះបានប្រកាសសម្រាកមួយសប្តាហ៍។ អង្គជំនុំជម្រះបានកំណត់បន្តកិច្ចដំណើរការនីតិវិធីវិញ នៅថ្ងៃចន្ទ ទី០១ ខែតុលា ឆ្នាំ២០១២។ | http://krttrialmonitor.files.wordpress.com/2012/09/37-week-32-25-september-2012-kh.pdf |
| ៣៨ | សប្តាហ៍ទី៣៣<br>ថ្ងៃទី០១ ខែតុលា<br>- ទី០៤ ខែតុលា<br>ឆ្នាំ២០១២ | នាសប្តាហ៍នេះ អង្គជំនុំជម្រះបានចាប់ផ្តើមស្តាប់សក្ខីកម្មរបស់លោក **ខៀវ អេន** ជាបុគ្គល ម្នាក់ដែលធ្លាប់មានភារកិច្ចទទួលខុសត្រូវនៅក្នុងក្រសួងឃោសនាការ និងអប់រំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់មក អង្គជំនុំជម្រះ បានចំណាយពេលក្នុងការអានសម្រង់ពីដីកាដំណោះស្រាយ ទាក់ទងនឹងរចនាសម្ព័ន្ធយោធា និងការផ្លាស់ទីប្រជាជន ដែលប្រធានបទនេះស្ថិតនៅក្នុងដំណាក់កាលទីបីនៃសំណុំរឿង០០២/១។ បន្ទាប់មក អង្គជំនុំជម្រះបានកោះហៅអតីតមន្ត្រីយោធាម្នាក់ក្នុងរបបខ្មែរក្រហម គឺលោក **មាស រឿន** មកកាន់សវនាការដើម្បីផ្តល់សក្ខីកម្ម ។<br>ជនជាប់ចោទ **អៀង សារី** បានបន្តអវត្តមានក្នុងកិច្ចដំណើរការសវនាការពេញមួយសប្តាហ៍ ដោយគាត់បានលះបង់សិទ្ធិមានវត្តមានក្នុងការស្តាប់សក្ខីកម្មរបស់លោក **ខៀវ អេន** និងលោក **មាស រឿន**។ កាលពីរសៀលថ្ងៃអង្គារ អង្គជំនុំជម្រះ បានសម្រេចអញ្ជើញភាគីទាំងអស់ឲ្យដាក់សំណើ ផ្ទាល់មាត់អំពីរបៀបដែលត្រូវបន្តដំណើរការកាត់សេចក្តីរបស់ **អ.វ.ត.ក** ដើម្បីឲ្យឆ្លើយតបទៅនឹងស្ថានភាពសុខភាពដ៏យ៉ាប់យ៉ឺនរបស់ជនជាប់ចោទលោក **អៀង សារី**។ បញ្ហា | http://krttrialmonitor.files.wordpress.com/2012/10/38_week-33_hearing-on-evidence_1-4-oct-2012_kh.pdf |

| | | | |
|---|---|---|---|
| | | ផ្សេងៗទៀតទាក់ទងនឹងការគ្រប់គ្រងតុលាការ ក៏ត្រូវបានលើកឡើងផងដែរនាសប្តាហ៍នេះ។ អង្គជំនុំជម្រះ បានខិតខំប្រឹងប្រែងគួរឲ្យកត់សម្គាល់នៅក្នុងការធានាឲ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តិទៅបានលឿន និងល្អប្រសើរ ស្របពេលដែលក្រុមមេធាវីការពារក្តីជនជាប់ចោទ **នួន ជា** ក៏បានព្យាយាមការពារសិទ្ធិកូនក្តីរបស់ពួកគេ ឲ្យទទួលបាននូវការគោរពសិទ្ធិស្មើៗគ្នាដូចភាគីដទៃទៀតនៃសំណុំរឿង ។ | |
| ៣៩ | សប្តាហ៍ទី៣៤<br>ថ្ងៃទី០៨ ខែតុលា - ទី១០ ខែតុលា ឆ្នាំ២០១២ | ក្នុងការចូលរួមប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិ អង្គជំនុំជម្រះបានដំណើរការសវនាការតែបីថ្ងៃប៉ុណ្ណោះនាសប្តាហ៍នេះ។ នៅថ្ងៃចន្ទ និងថ្ងៃអង្គារ សវនាការបានបន្តស្តាប់សក្ខីកម្មសាក្សី **មាស វឿន** ដែលជាទាហានខ្មែរក្រហមម្នាក់ និងក្រោយមក បានក្លាយជាមេបញ្ជាការរងនៃកងពលធំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណែកឯ រសៀលថ្ងៃអង្គារ អង្គជំនុំជម្រះបានឲ្យក្រឡាបញ្ជីអានអង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងវាលពិឃាតទួលពោធិ៍ជ្រៃ បន្ថែមលើផ្នែកមាននៅក្នុងសវនាការវគ្គទីបីនៃសំណុំរឿង០០២/០១ ដែលបានអានកាលពីសប្តាហ៍មុន។ កាលពីថ្ងៃពុធ ដែលជាថ្ងៃចុងសប្តាហ៍ សហព្រះរាជអាជ្ញាបានចាប់ផ្តើមដាក់បង្ហាញឯកសារទាក់ទងនឹងសវនាការវគ្គទី៣។<br>សវនាការរយៈពេលបីថ្ងៃនេះ អង្គជំនុំជម្រះក៏បានចំណាយពេលវេលាដោះស្រាយនូវបញ្ហាច្បាប់ និងនីតិវិធី ដែលបានលើកឡើង រួមមានដូចជា៖ (ក) ការប្រើប្រាស់ឯកសារដែលទទួលបានពីការទារុណកម្ម (ខ) នីតិវិធីក្នុងការ “ដកចេញ” នូវសេចក្តីថ្លែងការណ៍ពីកំណត់ហេតុរបស់សហចៅក្រមស៊ើបអង្កេត (គ) ការសួរដេញដោលស្តីពីការមិនធ្វើកំណត់ត្រាយោងលើឯកសារ ឬសេចក្តីថ្លែងការណ៍មុនៗ (ឃ) ភាពជឿជាក់បាននៃការកំណត់ហេតុស្តីពីកិច្ចសម្ភាសន៍របស់សហចៅក្រមស៊ើបអង្កេត និង (ង) សំណួរដែលមានចេតនានាំមុខសាក្សី។ បន្ថែមលើសពីនេះ ជនជាប់ចោទ **នួន ជា** ត្រូវបានអនុញ្ញាតឲ្យបញ្ចេញជាមតិយោបល់ដើម្បីស្រាយបំភ្លឺអំពីអង្គហេតុនៅក្នុងដីកាដំណោះស្រាយ។ | http://krttrialmonitor.files.wordpress.com/2012/10/39-e296a0-week-34-e296a0-8-10-october-2012.pdf |
| ៤០ | សប្តាហ៍ទី៣៥<br>ថ្ងៃទី១៨ ខែតុលា - ទី១៩ ខែតុលា ឆ្នាំ២០១២ | បន្ទាប់ពីសម្រាកពិធីបុណ្យភ្ជុំបិណ្ឌ សវនាការបានចាប់ផ្តើមឡើងវិញនៅថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រនៅក្នុងសប្តាហ៍នេះ។ សហព្រះរាជអាជ្ញា បានបន្តដាក់បង្ហាញឯកសារភស្តុតាងបន្តពីសប្តាហ៍មុន និងឱកាសបន្ទាប់ជាវេនរបស់មេធាវីរដើមបណ្តឹងរដ្ឋប្បវេណី។ ទោះបីជាមានតែក្រុមមេធាវីការពារក្តីឲ្យលោក **នួន ជា** បានដាក់ឯកសារក៏ដោយ ក៏ក្រុមមេធាវីការពារក្តីដទៃទៀត បានមានវត្តមាន ហើយធ្វើការជំទាស់ និងបានដាក់ជាសំណើនានា ជាពិសេសពាក់ព័ន្ធនឹងវិធានក៏ដូចជាគោលបំណងនៃសវនាការលើឯកសារ។<br>សវនាការលើឯកសារ បានបញ្ចប់មុនការរំពឹងទុក ដូច្នេះ អង្គជំនុំជម្រះបានកោះហៅដើមបណ្តឹងរដ្ឋប្បវេណី **យឹម សុវណ្ណ** មកផ្តល់សក្ខីកម្មនៅរសៀលថ្ងៃសុក្រ។ អ្នកស្រី បានផ្តល់សក្ខីកម្មផ្តោតសំខាន់ទៅលើបទពិសោធន៍មុនពេល និងក្នុងអំឡុងពេលខ្មែរក្រហមឡើងកាន់កាប់អំណាច ជាពិសេស អំពីស្ថានភាពក្រុមគ្រួសាររបស់អ្នកស្រី ដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៧៥ និងការជម្លៀសលើកទីពីរពីខេត្តកណ្តាលនៅឆ្នាំ១៩៧៦។ | http://krttrialmonitor.files.wordpress.com/2012/11/40-e296a0-week-35-e296a0-18-19-october-2012-e296a0-kh.pdf |